# ថ្នាំវ៉ាក់សុីនចាក់បង្ការរោគ កញ្ជ្រិល, ស្រឡទែន និង ស្អូច

## អ្វីដែលលោកអ្នកត្រូវការដឹង

## 1 ហេតុអ្វីបានជាចាក់ថ្នាំបង្ការរោគ ?

**រោគកញ្ជ្រិល, រោគស្រឡទែន និងរោគស្អូច គឺជារោគធ្ងន់ធ្ងរមួយ។**

កញ្ជ្រិល
- មេរោគកញ្ជ្រិលធ្វើឲ្យឡើងពងលើស្បែក, ក្អក, ហៀរសំបោរ, ក្រហាយភ្នែក ហើយនិងគ្រុន។
- វាអាចនាំអោយមានដំបៅត្រចៀក, ជម្ងឺហើមទងសួត, ប្រកាច់ (ភ្ញាក់ ឬ បើកភ្នែកធំៗសម្លឹងក្រឹសៗ) ខូចប៉ះពាល់ដល់ខួរក្បាល ហើយអាចស្លាប់បាន។

ស្រឡទែន
- មេរោគស្រឡទែនធ្វើឲ្យគ្រុន, ឈឺក្បាល ហើយនិងហើមក្រពេញនៅខាងក្រោមថ្គាម។
- វាអាចនាំអោយថ្លង់, ជម្ងឺរលាកស្រោមខួរ (រោគដំបៅខួរក្បាលនិងសរសៃព័ទជុំវិញ) ហើមឈឺចុកចាប់ពងក្ពូ ឬយោនី ហើយនិងកម្រស្លាប់។

ស្អូច (រោគកញ្ជ្រិលអាល្លឺម៉ង់)
- មេរោគស្អូចធ្វើឲ្យឡើងពងលើស្បែក, គ្រុនធម្មតា ហើយនិងឈឺចុកចាប់សន្លាក់ឆ្អឹង (ភាគច្រើនជាស្ត្រីភេទ)។
- បើសិនជាស្ត្រីមានរោគស្អូចនៅពេលមានផ្ទៃពោះ, ស្ត្រីនោះអាចរលូតកូន ឬទារកអាចកើតមកមានជម្ងឺជាប់ជាមួយយ៉ាងធ្ងន់ធ្ងរ។

លោកអ្នក ឬកូនលោកអ្នកអាចទទួលឆ្លងរោគទាំងអស់នេះដោយនៅជិតស្និតមនុស្ស ដែលមានមេរោគនោះ។ មេរោគនេះ វាសាយភាយហើរឆ្លងមកពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមខ្យល់។

**ថ្នាំចាក់ វ៉ាក់សុីន សំរាប់រោគកញ្ជ្រិល, ស្រឡទែន និងស្អូច (MMR) អាចការពាររោគទាំងអស់នេះ បាន។**

ក្មេងភាគច្រើនដែលបានចាក់ថ្នាំវ៉ាក់សុីនការពារ MMR នឹងមិនអាចមានរោគទាំងអស់នេះឡើយ។ វាអាចមានក្មេងច្រើនថែមទៀតមានរោគទាំងអស់នេះ បើសិនជាយើងឈប់ចាក់ថ្នាំវ៉ាក់សុីនបង្ការរោគនេះ។

## 2 តើអ្នកណាគួរចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ MMR ហើយនៅពេលណា ?

**ក្មេងទាំងឡាយគួរតែចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ** MMR 2 ដង :

✓ ចាក់លើកដំបូងនៅពេលមាន**អាយុ 12-15 ខែ**

✓ ហើយលើកទីពីរនៅពេលមាន**អាយុ 4-6 ឆ្នាំ។**

MMR VIS - (1/15/03) Cambodian

ទាំងនេះគឺអាយុត្រូវចាក់ថ្នាំ។ ប៉ុន្តែ កូនក្មេងអាចទទួលចាក់ថ្នាំលើកទីពីរនៅពេលណាក៏បាន អោយតែបានក្រោយពី 28 ថ្ងៃពីបានចាក់លើកដំបូងហើយ។

មនុស្សពេញវ័យខ្លះ **គួរតែចាក់ថ្នាំវ៉ាក់សុីនការពាររោគ** MMR ផងដែរ : ជាទូទៅ មនុស្សមានអាយុ 18 ឆ្នាំ ឬអាយុច្រើនជាងនេះ ដែលបានកើតក្រោយឆ្នាំ 1956 គួរតែចាក់ថ្នាំវ៉ាក់សុីនការពាររោគ MMR យ៉ាងហោចបានម្តង, លុះណាតែបុគ្គលនោះបានបង្ហាញឃើញ ថាបានចាក់ថ្នាំវ៉ាក់សុីន ឬមានរោគទាំងឡាយនោះ។

សូមសាកសួរលោកវេជ្ជបណ្ឌិត ឬគ្រូពេទ្យសំរាប់ព័តមានបន្ថែម។

ថ្នាំវ៉ាក់សុីនការពាររោគ MMR ប្រហែលជាអាចចាក់អោយទទឹមគ្នានិងថ្នាំវ៉ាក់សុីនផ្សេងៗទៀតបាន។

## 3 មនុស្សខ្លះមិនគួរចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ MMR ឬគួររង់ចាំ

- មនុស្សដែលមិនគួរចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ MMR គឺជាមនុស្សដែលធ្លាប់មាន **ប្រតិកម្មទាស់ដល់អាយុជីវិតដល់ជាតិខាប់អន្ទិល, ថ្នាំបដិបក្ខប្រាណ neomycin, ឬដល់ការចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ MMR ពីមុនមក។**
- មនុស្សដែលឈឺមិនធ្ងន់ធ្ងរ ឬធ្ងន់ធ្ងរមធ្យមនៅពេលកំណត់ចាក់ថ្នាំនោះ គួរតែរង់ចាំរហូតដល់ជាស្រួលឡើងវិញសិន មុននឹងចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ MMR ។
- ចំពោះស្ត្រីមានផ្ទៃពោះគួរតែរង់ចាំមិនទាន់ចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ MMR រហូតដល់សំរាលកូនរួចហើយសិន។ ស្ត្រីទាំងឡាយគួរតែជៀសវាងមានផ្ទៃពោះបាន 4 អាទិត្យក្រោយពីបានចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ MMR រួច។
- ចំពោះមនុស្សខ្លះគួរតែទាក់ទងមកវេជ្ជបណ្ឌិតរបស់ខ្លួនអំពីការគួរចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ MMR រួមទាំងមនុស្សដែលមាន :
  - រោគ HIV/AIDS ឬក៏មេរោគផ្សេងៗដែលប៉ះពាល់ដល់ប្រព័ន្ធការពារក្នុងខ្លួន
  - កំពុងតែប្រើប្រាស់ថ្នាំព្យាបាលរោគដែលប៉ះពាល់ដល់ប្រព័ន្ធការពារក្នុងខ្លួន ដូចជាថ្នាំ steroids ចំនួន 2 អាទិត្យ ឬយូរជាងនេះ។
  - មានរោគមហារីកណាមួយ
  - កំពុងតែព្យាបាលរោគមហារីកដោយថតកាំរស្មី-អ៊ិច ឬថ្នាំសង្កូវ
  - ធ្លាប់មានចំនួនកោសិកាតូចៗទាប (ឈាមវិបល្លាស)
- ចំពោះមនុស្សដែលថ្មីៗនេះមានចាក់បញ្ចូលឈាម ឬបានទទួលឈាមផ្សេងៗ គួរតែសាកសួរវេជ្ជបណ្ឌិតរបស់គេ នៅពេលណាគេអាចចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ MMR បាន

សូមសាកសួរលោកវេជ្ជបណ្ឌិត ឬគ្រូពេទ្យសំរាប់ព័តមានបន្ថែម។

*ម្ខាងទៀត . . .*

## 4 តើអ្វីខ្លះដែលជាការគ្រោះថ្នាក់ពីថ្នាំវ៉ាក់ស៊ីនចាក់បង្ការរោគ **MMR** នោះ ?

ថ្នាំវ៉ាក់ស៊ីន ក៏ដូចជាថ្នាំផ្សេងៗទៀតដែរ គឺមានឥទ្ធិពលអាចធ្វើឲ្យមានបញ្ហាធ្ងន់ធ្ងរ ដូចជាប្រតិកម្មទាស់និងអ្វីមួយធ្ងន់ធ្ងរ។ ការគ្រោះថ្នាក់ពីថ្នាំវ៉ាក់ស៊ីនចាក់បង្ការរោគ MMR ធ្វើឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ, ឬ ស្លាប់នោះ គឺវាកម្រមានណាស់។

ការទទួលចាក់ថ្នាំវ៉ាក់ស៊ីនបង្ការរោគ MMR គឺមានសុវត្ថិភាពជាងការទទួលមានមេរោគទាំងឡាយនោះ។

មនុស្សភាគច្រើនដែលចាក់ថ្នាំវ៉ាក់ស៊ីនបង្ការរោគ MMR ពុំមានបញ្ហានិងថ្នាំនេះឡើយ។

### បញ្ហាមិនធ្ងន់ធ្ងរ

- គ្រុន (មានដល់ទៅមនុស្សម្នាក់ក្នុងចំណោមមនុស្ស 6 នាក់)
- ឡើងពងលើស្បែកមិនធ្ងន់ (មានប្រមាណមនុស្សម្នាក់ក្នុងចំណោមមនុស្ស 20 នាក់)
- ហើមកូនកណ្ដុរនៅលើថ្ពាល់ ឬក (កម្រមាន)

បើសិនជាមានបញ្ហាទាំងនេះកើតឡើង ជាទូទៅវាកើតមានឡើងក្នុងកំឡុងពេល 7-12 ថ្ងៃក្រោយពីបានចាក់ថ្នាំរួច។ បញ្ហាទាំងនេះកើតមានឡើងកាន់តែតិចក្រោយពីចាក់ថ្នាំលើកទីពីរ។

### បញ្ហាធ្ងន់ធ្ងរមធ្យម

- ប្រកាច់ (ញាក់ញ័រ ឬបើកភ្នែកសម្លឹកធំៗ) ដែលបណ្ដាលមកពីគ្រុន (ប្រមាណ 1 ក្នុងចំណោមចាក់ 3,000 ម្ដង)
- ឈឺចាប់បន្តិចបន្តួច ឬការកំរើកមិនបានក្នុងសន្លាក់, ភាគច្រើនចំក្មេងជំទង់ ឬស្ត្រីពេញវ័យ (មានដល់ទៅ 1 ក្នុងចំណោម 4)
- មានចំនួនកោសិកាតូចៗទាបម្ដងម្កាល ដែលអាចធ្វើឲ្យធ្លាក់វិបល្លាសឈាម (ប្រមាណ 1 ក្នុងចំណោមចាក់ 30,000 ដង)

### បញ្ហាធ្ងន់ធ្ងរ (កម្រមានណាស់)

- មានប្រតិកម្មទាស់ធ្ងន់ធ្ងរ (មានតិចជាង 1 ក្នុងចំណោមចាក់មួយលានដង)
- បញ្ហាធ្ងន់ធ្ងរពីរបីផ្សេងទៀតដែលធ្លាប់មានកើតឡើង ក្រោយពេលក្មេងបានចាក់ថ្នាំវ៉ាក់ស៊ីនបង្ការរោគ MMR ។ ក៏ប៉ុន្តែបញ្ហានេះកម្រកើតមានណាស់, អ្នកឯកទេសមិនអាចដឹងច្បាស់ថា បញ្ហាទាំងនោះកើតមានឡើងដោយសារតែថ្នាំវ៉ាក់ស៊ីនឬយ៉ាងណានោះទេ។ នេះរួមទាំង :
  - ការថ្លង់
  - ប្រកាច់យូរអង្វែង, សន្លប់ ឬបន្ថយការដឹងខ្លួនឯង
  - ខូចខួរក្បាលជាអចិន្ត្រៃយ

## 5 តើត្រូវធ្វើយ៉ាងណា បើសិនជាមានប្រតិកម្មធ្ងន់ធ្ងរមធ្យម ឬធ្ងន់ធ្ងរនោះ ?

### តើឲ្យខ្ញុំសង្កេតមើលអ្វី ?

លក្ខណៈចម្លែកណាមួយ ដូចជាប្រតិកម្មទាស់ធ្ងន់ធ្ងរ, គ្រុនក្ដៅខ្លស់ ឬមានការផ្លាស់ប្ដូរអាកប្បកិរិយា។ សញ្ញាបង្ហាញនៃប្រតិកម្មទាស់ធ្ងន់ធ្ងរ រួមទាំងការពិបាកដង្ហើម, សម្លេងស្អក ឬសម្លេងតូចស្រាល, កន្ទួលរមាស់បណ្ដាលមកពីទាស់ចំណី, ស្លេកស្លាំង, បេះដូងដើរលឿន ឬវិលមុខពីរពោងក្នុងពេល ពីរបីនាទីដល់ពីរបីម៉ោងក្រោយពីបានចាក់ថ្នាំរួច។ គ្រុនក្ដៅខ្លស់ ឬប្រកាច់, បើសិនជាមានកើតឡើងប្រហែលជាអាចកើតឡើងក្នុង 1 ឬ 2 អាទិត្យក្រោយពីបានចាក់ថ្នាំរួច។

### តើគួរឲ្យខ្ញុំធ្វើយ៉ាងណា ?

- ចូរទូរស័ព្ទទៅវេជ្ជបណ្ឌិត ឬយកមនុស្សមានជម្ងឺទៅជួបវេជ្ជបណ្ឌិតភ្លាម។
- ចូរប្រាប់វេជ្ជបណ្ឌិតអ្វីបានកើតឡើង, ខែថ្ងៃឆ្នាំ និងពេលវេលាបានកើតឡើង ហើយនិងពេលបានចាក់ថ្នាំវ៉ាក់ស៊ីនបង្ការរោគនោះ។
- សាកសួរវេជ្ជបណ្ឌិត, គ្រូពេទ្យរបស់លោកអ្នក ឬមន្ទីរសុខាភិបាល ដើម្បីដាក់ពាក្យប្ដឹងតវ៉ាអំពីព្រឹត្តិការណ៍រាំងប្រព័ន្ធថ្នាំវ៉ាក់ស៊ីន (Vaccine Adverse Event Reporting System, VAERS) ។

  ឬលោកអ្នកអាចដាក់ពាក្យប្ដឹងតវ៉ារបាយការណ៍នេះតាមគេហទំព័រកុំព្យូទ័ររបស់ VAERS តាមអាសយដ្ឋាន www.vaers.hhs.gov, ឬតាមទូរស័ព្ទលេខ 1-800-822-7967 ។

  *មណ្ឌល VAERS មិនផ្ដល់ឳវាទផ្នែកខាងសុខភាពទេ។*

## 6 កម្មវិធីជាតិផ្ដល់ជំនួយដល់ការមានគ្រោះថ្នាក់ពីថ្នាំវ៉ាក់ស៊ីន **(The National Vaccine Injury Compensation Program)**

នៅក្នុងព្រឹត្តិការណ៍កម្រមានដែលលោកអ្នក ឬកូនរបស់លោកអ្នកមានប្រតិកម្មធ្ងន់ធ្ងរទាស់ដល់ថ្នាំ វ៉ាក់ស៊ីន, កម្មវិធីសហពន្ធបានបង្កើត ដើម្បីជួយលោកអ្នកបង់ថ្លៃមើលព្យាបាលលើមនុស្សដែលបានទទួលរងគ្រោះ។

ចំពោះព័តមានបន្ថែមអំពីកម្មវិធីជាតិផ្ដល់ជំនួយដល់ការមានគ្រោះថ្នាក់ពីថ្នាំវ៉ាក់ស៊ីន, ចូរទូរស័ព្ទមកលេខ **1-800-338-2382** ឬទស្សនាកម្មវិធីតាមគេហទំព័រ www.hrsa.gov/vaccinecompensation

## 7 តើអាចឲ្យខ្ញុំសិក្សាអំពីរឿងបន្ថែមដោយរបៀបណាដែរ ?

- សាកសួរវេជ្ជបណ្ឌិត ឬគ្រូពេទ្យរបស់លោកអ្នក។ វេជ្ជបណ្ឌិត/គ្រូពេទ្យអាចផ្ដល់ឲ្យលោកអ្នកនៅកញ្ចប់ថ្នាំវ៉ាក់ស៊ីនជាដំណឹង ឬឃោបល់អំពីប្រភពព័តមានផ្សេងៗ។
- ទូរស័ព្ទមន្ទីរសុខាភិបាលក្នុងតំបន់ ឬមន្ទីរសុខាភិបាលរដ្ឋអំពីកម្មវិធីចាក់ថ្នាំបង្ការរោគ។
- ទាក់ទងមកមណ្ឌលទប់ស្កាត់ និងការពាររោគ (Centers for Disease Control and Prevention, CDC):
  - ទូរស័ព្ទលេខ **1-800-232-4636 (1-800-CDC-INFO)**
  - ទស្សនាគេហទំព័រកម្មវិធីជាតិចាក់ថ្នាំបង្ការរោគ www.cdc.gov/nip

**U.S. DEPARTMENT OF HEALTH & HUMAN SERVICES**
Centers for Disease Control and Prevention
National Immunization Program

Vaccine Information Statement
MMR IMM-354CA-Cambodian (1/15/03) 42 U.S.C. § 300aa-26
Translated by Transcend Translations, Davis, CA
http://www.transcend.net